Australian Government

mediation resolve agreement confidential differences child-focused neutral safe

Khmer | ភាសាខ្មែរ

# ដំណោះស្រាយវិវាទគ្រួសារ

រដ្ឋាភិបាលអូស្ត្រាលីផ្តល់មូលនិធិដល់សេវាកម្មដោះស្រាយវិវាទគ្រួសារដើម្បីជួយគ្រួសារអូស្ត្រាលីឱ្យពិភាក្សា និងយល់ព្រមលើការរៀបចំចាត់ចែងដែលបំពេញផលប្រយោជន៍ដ៏ល្អបំផុតសម្រាប់កូនៗរបស់ពួកគេដោយមិនចាំបាច់ទៅតុលាការ។

## តើការដោះស្រាយវិវាទគ្រួសារ (FDR) គឺជាអ្វី?

ការដោះស្រាយវិវាទគ្រួសារ (FDR) គឺជាប្រភេទនៃការសម្រុះសម្រួលដែលជួយឱ្យគ្រួសារដែលបែកគ្នាឈានដល់កិច្ចព្រមព្រៀងផ្ទាល់ខ្លួនរបស់ពួកគេដោយមិនចាំបាច់ទៅតុលាការ។ FDR អាចជួយមនុស្សឱ្យព្រមព្រៀងលើបញ្ហាជាច្រើនដែលទាក់ទងនឹងទ្រព្យសម្បត្តិ លុយកាក់ និងសំខាន់បំផុតគឺកូនៗរបស់ពួកគេ។

សេវាកម្ម FDR ត្រូវបានផ្តល់ដោយបុគ្គល និងអង្គការជាច្រើន ឧទាហរណ៍ មជ្ឈមណ្ឌលទំនាក់ទំនងគ្រួសារ អង្គការសហគមន៍ គណៈកម្មការជំនួយផ្នែកច្បាប់ និងបុគ្គលនានាដែលផ្តល់ជូនសេវាកម្ម FDR ឯកជន (បង់ប្រាក់)។ ប្រសិនបើអ្នកស្ថិតនៅក្នុងតំបន់ដាច់ស្រយាលឬមិនអាចទៅដល់អ្នកផ្តល់សេវា អ្នកក៏អាចចូលប្រើសេវាកម្ម FDR តាមរយៈទូរសព្ទឬសន្និសីទវីដេអូផងដែរ។

មានតែអ្នកប្រកបវិជ្ជាជីវៈ FDR ដែលមានការទទួលស្គាល់ជាផ្លូវការប៉ុណ្ណោះត្រូវបានអនុញ្ញាតឱ្យផ្តល់សេវាកម្ម FDR។ អ្នកអាចពិនិត្យមើល បញ្ជីដំណោះស្រាយវិវាទគ្រួសារ (https://fdrr.ag.gov.au/) ដើម្បីបញ្ជាក់ថាតើនរណាម្នាក់ជាអ្នកប្រកបវិជ្ជាជីវៈ FDR ដែលមានការទទួលស្គាល់ជាផ្លូវការឬអត់។

## តើ FDR ជាការចាំបាច់ទេ?

ឪពុកម្តាយដែលបែកគ្នាត្រូវបានច្បាប់តម្រូវឱ្យព្យាយាម FDR មុនពេលពួកគេអាចដាក់ពាក្យទៅតុលាការច្បាប់គ្រួសារសម្រាប់ដីកាចិញ្ចឹមកូន លុះត្រាតែការលើកលែងមួយឬច្រើនដូចខាងក្រោមត្រូវបានអនុវត្ត៖

- អ្នកកំពុងធ្វើកិច្ចព្រមព្រៀងជាផ្លូវការតាមរយៈ 'ដីកាការយល់ព្រម'
- អំពើហិង្សាក្នុងគ្រួសារ ឬការរំលោភបំពានលើកុមារបានកើតឡើង
- អ្នកកំពុងឆ្លើយតបទៅនឹងពាក្យសុំទៅតុលាការ
- ការសម្រេចចិត្តចាំបាច់ត្រូវធ្វើជាបន្ទាន់
- មនុស្សម្នាក់មិនអាចចូលរួមក្នុង FDR បាន
- មនុស្សម្នាក់មិនបានអនុវត្តតាម ឬបានបង្ហាញការមិនគោរពយ៉ាងធ្ងន់ធ្ងរចំពោះដីការបស់តុលាការដែលបានធ្វើឡើងក្នុងរយៈពេល 12 ខែចុងក្រោយនេះ។

សូម្បីតែមនុស្សដែលធ្លាប់ទៅតុលាការក៏អាចត្រូវព្យាយាម FDR បានដែរ ប្រសិនបើពួកគេត្រូវការដីកាតុលាការថ្មី ឬផ្លាស់ប្តូរដីកាបច្ចុប្បន្ន។

ប្រសិនបើមិនមានការលើកលែងទេ អ្នកនឹងត្រូវដាក់វិញ្ញាបនបត្រមួយពីអ្នកប្រកបវិជ្ជាជីវៈ FDR ដើម្បីឱ្យមានការកំណត់ពីបញ្ហាការចិញ្ចឹមកូនដែលកំណត់ដោយតុលាការច្បាប់គ្រួសារ។ វិញ្ញាបនបត្រអាចចេញបានតែដោយអ្នកប្រកបវិជ្ជាជីវៈ FDR ដែលបានទទួលស្គាល់ជាផ្លូវការនៅក្រោមបទប្បញ្ញត្តិនៃច្បាប់គ្រួសារ (អ្នកប្រកបវិជ្ជាជីវៈក្នុងការដោះស្រាយវិវាទគ្រួសារ) ឆ្នាំ 2025 ប៉ុណ្ណោះ។

## តើអ្នកប្រកបវិជ្ជាជីវៈ FDR នឹងផ្តល់ព័ត៌មានអ្វីខ្លះដល់ខ្ញុំ?

មុនពេលអ្នកចាប់ផ្តើម FDR, អ្នកប្រកបវិជ្ជាជីវៈ FDR របស់អ្នកត្រូវតែប្រាប់អ្នកអំពីគុណវុឌ្ឍិរបស់ពួកគេ ដំណើរការ FDR រួមទាំងការការពារអ្វីខ្លះដែលអនុវត្តចំពោះអ្វីៗដែលអ្នកនិយាយនៅក្នុង FDR តើវានឹងចំណាយអស់ប៉ុន្មាន និងព័ត៌មានលម្អិតអំពីរបៀបដែលអ្នកអាចធ្វើបណ្តឹងតវ៉ាអំពីសេវាកម្មនេះ។ ពួកគេក៏អាចប្រាប់អ្នកអំពីសេវាកម្មផ្សេងទៀតដែលអាចជួយអ្នកបានដែរ។ អ្នកប្រកបវិជ្ជាជីវៈ FDR ក៏ត្រូវតែផ្តល់ឱ្យអ្នកនូវព័ត៌មានអំពីការចូលរួម FDR មុនពេលដាក់ពាក្យទៅតុលាការ របៀបទទួលបានវិញ្ញាបនបត្រផ្នែក 60I ហើយថាតុលាការអាចគិតពិចារណាវិញ្ញាបនបត្រនោះនៅពេលធ្វើសេចក្តីសម្រេចតម្រូវឱ្យបង់ការចំណាយប្រឆាំងនឹងមនុស្សម្នាក់។

ប្រសិនបើអ្នកកំពុងព្យាយាមដោះស្រាយការមិនយល់ស្របគ្នាអំពីកូនរបស់អ្នក អ្នកនឹងត្រូវបានលើកទឹកចិត្តឱ្យធ្វើសកម្មភាពជាផលប្រយោជន៍ល្អបំផុតរបស់កូនរបស់អ្នក។

ប្រសិនបើអ្នកកំពុងព្យាយាមដោះស្រាយការមិនយល់ស្របអំពីហិរញ្ញវត្ថុ ឬទ្រព្យសម្បត្តិ អ្នកប្រកបវិជ្ជាជីវៈត្រូវតែផ្តល់ឱ្យអ្នកនូវព័ត៌មានអំពីកាតព្វកិច្ចរបស់អ្នកក្នុងការលាតត្រដាងព័ត៌មាន និងឯកសារហិរញ្ញវត្ថុដែលពាក់ព័ន្ធទាំងអស់ទៅគ្នាទៅវិញទៅមក ក៏ដូចជាទៅតុលាការ។

## តើអ្នកណាអាចទៅ FDR?

មនុស្សដែលមានការមិនយល់ស្របចាំបាច់ត្រូវចូលរួមក្នុងដំណើរការ FDR។ ប្រសិនបើវាសមស្រប អ្នកអាចនាំសមាជិកគ្រួសារ ឬអ្នកគាំទ្រម្នាក់មកជាមួយអ្នក រួមទាំងមេធាវីរបស់អ្នក។ ទោះជាយ៉ាងណាក៏ដោយ អ្នកប្រកបវិជ្ជាជីវៈ FDR ត្រូវតែយល់ព្រមឱ្យមនុស្សផ្សេងទៀតមកក្នុងវគ្គ FDR។ ប្រសិនបើអ្នកមានគម្រោងនាំអ្នកគាំទ្រ ឬមេធាវីមកជាមួយអ្នក អ្នកគួរតែពិភាក្សារឿងនេះជាមួយអ្នកប្រកបវិជ្ជាជីវៈ FDR ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។

## តើកូនរបស់ខ្ញុំនឹងត្រូវបានរួមបញ្ចូលនៅក្នុង FDR ដែរឬទេ?

ទេ ប៉ុន្តែអាស្រ័យលើកាលៈទេសៈរបស់អ្នក និងកត្តាជាច្រើនដូចជាអាយុ និងភាពចាស់ទុំនៃកូនរបស់អ្នក អ្នកប្រឹក្សាគ្រួសារ ឬអ្នកចិត្តសាស្ត្រកុមារអាចនិយាយជាមួយកូនរបស់អ្នកបាន។ នេះនឹងកើតឡើងដោយមានការយល់ព្រមពីឪពុកម្តាយប៉ុណ្ណោះ។

## តើមានអ្វីកើតឡើងនៅក្នុងអំឡុងពេល FDR?

មុនពេលការសម្រុះសម្រួលអាចចាប់ផ្តើម ការវាយតម្លៃនឹងត្រូវបានធ្វើឡើងដើម្បីមើលថាតើ FDR សមរម្យសម្រាប់ស្ថានភាពរបស់អ្នកដែរឬទេ។ អ្នកប្រកបវិជ្ជាជីវៈ FDR មិនលម្អៀង ហើយនឹងមិនកាន់ជើងភាគីណាទេ។ ពួកគេអាចជួយអ្នកក្នុងការស្វែងយល់ពីបញ្ហាគ្រួសារដែលមិនលំអៀង និងតាមវិធីវិជ្ជមាន។ មិនដូចការប្រឹក្សាទេ, FDR មិនផ្តោតលើផ្នែកអារម្មណ៍នៃទំនាក់ទំនងទេ។ វាផ្តោតលើការដោះស្រាយវិវាទជាក់លាក់។

អ្នកត្រូវបានលើកទឹកចិត្តឱ្យធ្វើការខិតខំប្រឹងប្រែងពិតប្រាកដដើម្បីព្យាយាមដោះស្រាយវិវាទដោយមានជំនួយពីអ្នកប្រកបវិជ្ជាជីវៈ FDR។

FDR អាចជួយអ្នកទាំងពីរក្នុងការពិភាក្សាអំពីបញ្ហានានា រកមើលជម្រើស និងរកវិធីដ៏ល្អបំផុតដើម្បីឈានដល់កិច្ចព្រមព្រៀង។ ជាសំខាន់ អ្នកអាចប្រើ FDR ដើម្បីបង្កើតផែនការចិញ្ចឹមកូនដើម្បីកំណត់ការរៀបចំចាត់ចែងសម្រាប់កូនរបស់អ្នក។ អ្នកប្រកបវិជ្ជាជីវៈ FDR ក៏នឹងពិនិត្យមើលថាមនុស្សគ្រប់គ្នាយល់ពីអ្វីដែលបាននិយាយ និងយល់ព្រម។

## តើមានអ្វីកើតឡើងប្រសិនបើអ្នកមានអារម្មណ៍ថាមិនមានសុវត្ថិភាព?

វាជារឿងសំខាន់ដែលអ្នកមានអារម្មណ៍ថាមានសុវត្ថិភាព និងមានសុវត្ថិភាពនៅមុនពេល ក្នុងអំឡុងពេល និងក្រោយ FDR។ ប្រសិនបើអ្នកមានការព្រួយបារម្ភអំពីសុវត្ថិភាពរបស់អ្នក ឬសុវត្ថិភាពរបស់កូនអ្នក អ្នកគួរតែប្រាប់អ្នកប្រកបវិជ្ជាជីវៈ FDR របស់អ្នក ឬបុគ្គលិកនៅសេវាកម្ម FDR ឱ្យបានឆាប់តាមដែលអាចធ្វើទៅបាន។ នេះអាចមានន័យថា FDR បញ្ឈប់ ឬមិនដំណើរការទៅមុខទៀត។ ភាគីនានារបស់ FDR ប្រហែលជាមិនចាំបាច់នៅក្នុងបន្ទប់តែមួយទេ។

មិនមានលក្ខខណ្ឌតម្រូវឱ្យធ្វើ FDR ទេ ប្រសិនបើមានអំពើហិង្សាក្នុងគ្រួសារ ឬការរំលោភបំពានលើកុមារ។

## តើវានឹងត្រូវចំណាយប៉ុន្មាន?

FDR អាចលឿន និងថោកជាងការទៅតុលាការ ឬការបង់ថ្លៃសេវាផ្នែកច្បាប់។ សេវាកម្ម FDR អាចគិតថ្លៃឈ្នួលយោងទៅតាមកាលៈទេសៈផ្នែកហិរញ្ញវត្ថុរបស់អ្នក។ អ្នកគួរតែអនុញ្ញាតឱ្យសេវាកម្ម FDR ដឹងប្រសិនបើអ្នកមានប្រាក់ចំណូលទាប ឬជួបការលំបាកផ្នែកហិរញ្ញវត្ថុ។

## តើអ្វីដែលបាននិយាយនៅ FDR មានលក្ខណៈសម្ងាត់ហើយតើរឿងដែលបាននិយាយទាំងនោះអាចត្រូវបានប្រើនៅក្នុងតុលាការទេ?

រឿងភាគច្រើនដែលអ្នកនិយាយនៅក្នុង FDR គឺមានលក្ខណៈសម្ងាត់ដរាបណាអ្នកកំពុងនិយាយជាមួយអ្នកប្រកបវិជ្ជាជីវៈ FDR ដែលមានការទទួលស្គាល់ជាផ្លូវការ។ ពេលខ្លះអ្នកប្រកបវិជ្ជាជីវៈ FDR អាចត្រូវបានតម្រូវដោយច្បាប់ដើម្បីបង្ហាញនូវអ្វី ដែលអ្នកបាននិយាយ ឧទាហរណ៍ ប្រសិនបើវាទាក់ទងនឹងការសង្ស័យថាមាន ការរំលោភបំពានលើកុមារ ឬដើម្បីការពារឧក្រិដ្ឋកម្មធ្ងន់ធ្ងរ ឬការគំរាមកំហែងដល់ជីវិត របស់នរណាម្នាក់។

មនុស្សដែលជាអ្នកប្រកបវិជ្ជាជីវៈ FDR មិនមានការទទួលស្គាល់ជាផ្លូវការ រួមទាំងមន្ត្រី ឬជំនួយការវាយតម្លៃតម្រូវការអតិថិជន មិនបានគ្របដណ្តប់ដោយការការពារភាពសម្ងាត់ទេ។ អ្នកគួរតែបញ្ជាក់ថាអ្នកប្រកបវិជ្ជាជីវៈ FDR របស់អ្នកគឺជាអ្នកប្រកបវិជ្ជាជីវៈដែលមានការទទួលស្គាល់ជាផ្លូវនៅមុនពេលអ្នកចាប់ផ្តើម FDR។ អ្នកអាចពិនិត្យមើលថាតើនរណាម្នាក់មានការទទួលស្គាល់ជាផ្លូវការនៅលើបញ្ជីដោះស្រាយវិវាទគ្រួសារដែរឬអត់។

អ្វីៗដែលអ្នកនិយាយនៅក្នុងអំឡុងពេល FDR មិនអាចត្រូវបានយកប្រើនៅក្នុងតុលាការ ឬនីតិវិធីណាមួយឡើយ លុះត្រាតែរឿងទាំងនោះទាក់ទងនឹងការរំលោភបំពានលើកុមារ។ នេះមានន័យថា ទោះបីជាអ្នកមិនអាចយល់ព្រមនៅក្នុង FDR ហើយអ្នកត្រូវទៅតុលាការក៏ដោយ ចៅក្រមនឹងមិនអាចប្រើអ្វីមួយដែលអ្នកនិយាយនៅក្នុងអំឡុងពេល FDR នៅពេលដែលពួកគេកំពុងធ្វើការសម្រេចចិត្តនៅក្នុងតុលាការទេ លុះត្រាតែវាទាក់ទងនឹងការរំលោភបំពានលើកុមារ។

ប្រសិនបើអ្នកប្រកបវិជ្ជាជីវៈ FDR របស់អ្នកបញ្ជូនអ្នកបន្តទៅមនុស្សផ្សេងសម្រាប់សេវាកម្មវិជ្ជាជីវៈ អ្វីៗដែលអ្នកនិយាយទៅកាន់បុគ្គលនោះក៏ត្រូវបានការពារផងដែរ ហើយនឹងមិនអាចទទួលយកបាននៅក្នុងតុលាការទេ លុះត្រាតែវាទាក់ទងនឹងការរំលោភបំពាន លើកុមារ។

## តើមានអ្វីកើតឡើងចំពោះកិច្ចព្រមព្រៀងណាមួយដែលបានឈានដល់នៅ FDR?

ប្រសិនបើអ្នកឈានដល់កិច្ចព្រមព្រៀងលើការរៀបចំចាត់ចែងសម្រាប់កូនរបស់អ្នក នេះអាចត្រូវបានកត់ត្រាជាផែនការចិញ្ចឹមកូន។ ផែនការចិញ្ចឹមកូនត្រូវតែជាលាយលក្ខណ៍អក្សរ បានចុះកាលបរិច្ឆេទ និងបានចុះហត្ថលេខាដោយឪពុកម្តាយទាំងពីរ។ ផែនការចិញ្ចឹមកូនរបស់អ្នកអាចរួមបញ្ចូលយន្តការនានាដើម្បីផ្លាស់ប្តូរការរៀបចំចាត់ចែង និងដោះស្រាយការមិនយល់ស្របគ្នានានា។ ផែនការចិញ្ចឹមកូនអាចត្រូវបានចរចាឡើងវិញទៅតាមពេលវេលា ប្រសិនបើចាំបាច់។

សូមដឹងថាការផ្លាស់ប្តូរណាមួយចំពោះការរៀបចំចាត់ចែងនៅក្នុងការថែទាំសម្រាប់កូនរបស់អ្នកអាចប៉ះពាល់ដល់ប្រាក់ជំនួយឧបត្ថម្ភកូន ការគាំទ្រប្រាក់ចំណូល និងប្រាក់ជំនួយគ្រួសារ។ បទប្បញ្ញត្តិពិសេសអនុវត្តអំពីការរួមបញ្ចូលប្រាក់ជំនួយឧបត្ថម្ភកូន នៅក្នុងផែនការចិញ្ចឹមកូនរបស់អ្នក។ ឧទាហរណ៍ ប្រសិនបើផែនការចិញ្ចឹមកូនរបស់អ្នកបញ្ជាក់ពីចំនួនទឹកប្រាក់សម្រាប់ប្រាក់ជំនួយឧបត្ថម្ភកូន នោះទីភ្នាក់ងារគ្រប់គ្រង *ប្រាក់ជំនួយឧបត្ថម្ភកូន* មិនអាចដាក់វាឱ្យអនុវត្តបានទេ លុះត្រាតែវាក៏ជាកិច្ចព្រមព្រៀងគាំទ្រកូនដែលមានសុពលភាពផងដែរ ហើយអ្នក ឬឪពុកម្តាយផ្សេងទៀតស្នើសុំទីភ្នាក់ងារគ្រប់គ្រង *ប្រាក់ជំនួយឧបត្ថម្ភកូន*ដើម្បីទទួលយកវា។

ប្រសិនបើអ្នកចង់ធ្វើកិច្ចព្រមព្រៀងផែនការចិញ្ចឹមកូនចុងក្រោយរបស់អ្នកអំពីការរៀបចំចាត់ចែងទ្រព្យសម្បត្តិ/ហិរញ្ញវត្ថុរបស់អ្នកដែលមានចំណងភ្ជាប់ស្របច្បាប់ អ្នកអាចដាក់ពាក្យទៅតុលាការដើម្បីឱ្យកិច្ចព្រមព្រៀងរបស់អ្នកបង្កើតជា ដីកាការយល់ព្រម។ អ្នកអាចធ្វើវាដោយខ្លួនឯង ឬស្នើសុំមេធាវីរបស់អ្នកឱ្យធ្វើវាសម្រាប់អ្នក។

## តើមានអ្វីកើតឡើងប្រសិនបើ FDR មិនដំណើរការ?

ទោះបីជាអ្នកមិនអាចឈានដល់កិច្ចព្រមព្រៀងក៏ដោយ, FDR អាចជួយអ្នក និងអតីតប្តីប្រពន្ធ ឬដៃគូរបស់អ្នកធ្វើទំនាក់ទំនងបានកាន់តែប្រសើរ ឬដោះស្រាយបានបញ្ហាខ្លះនៃបញ្ហានានារបស់អ្នក។ ប្រសិនបើអ្នកព្យាយាម FDR ប៉ុន្តែនៅតែត្រូវទៅតុលាការសម្រាប់ដីកាចិញ្ចឹមកូន អ្នកនឹងត្រូវការវិញ្ញាបនបត្រពីអ្នកប្រកបវិជ្ជាជីវៈ FDR ដែលមានការទទួលស្គាល់ជាផ្លូវការ។

វិញ្ញាបនបត្រនេះនឹងនិយាយពីចំណុចមួយក្នុងចំណោមចំណុចដូចខាងក្រោម៖

- អ្នក និងភាគីផ្សេងទៀតបានចូលរួម ហើយបានធ្វើការខិតខំប្រឹងប្រែងពិតប្រាកដដើម្បីដោះស្រាយវិវាទនេះ
- អ្នក និងភាគីផ្សេងទៀតបានចូលរួម ប៉ុន្តែម្នាក់ ឬទាំងពីរនាក់មិនបានធ្វើការខិតខំប្រឹងប្រែងពិតប្រាកដទេ
- ភាគីផ្សេងទៀតមិនបានចូលរួម
- អ្នកប្រកបវិជ្ជាជីវៈ FDR បានសម្រេចចិត្តថាករណីរបស់អ្នកមិនសមស្របសម្រាប់ FDR ឬ
- អ្នកប្រកបវិជ្ជាជីវៈ FDR បានសម្រេចចិត្តថាវាមិនសមស្របក្នុងការបន្តជាផ្នែកតាមរយៈដំណើរការ FDR។

អ្នកក៏គួរតែដឹងថាប្រសិនបើអ្នកមិនចូលរួម FDR ឬខិតខំប្រឹងប្រែងពិតប្រាកដដើម្បីចូលរួមទេ តុលាការក៏អាចបញ្ជាឱ្យអ្នកបង់ថ្លៃចំណាយផ្លូវច្បាប់ទៅឱ្យភាគីម្ខាងទៀតផងដែរ។

## តើខ្ញុំទាក់ទងអ្នកប្រកបវិជ្ជាជីវៈ FDR ដែលមានការទទួលស្គាល់ជាផ្លូវការដោយរបៀបណា?

សម្រាប់ព័ត៌មានបន្ថែមសូមហៅទូរសព្ទទៅ បណ្ដាញ ទូរសព្ទផ្ដល់ដំបូន្មានទំនាក់ទំនងគ្រួសារ តាមលេខ **1800 050 321** រវាងម៉ោង **8 ព្រឹក ដល់ម៉ោង 8 យប់ ពីថ្ងៃចន្ទ ដល់ថ្ងៃសុក្រ** និងពីម៉ោង **10 ព្រឹក ដល់ម៉ោង 4 រសៀល ថ្ងៃសៅរ៍** (លើកលែងតែថ្ងៃឈប់សម្រាកសាធារណៈ)។

ដើម្បីស្វែងរកសេវាកម្មដែលបានផ្ដល់មូលនិធិដោយរដ្ឋាភិបាល អ្នកអាចចូលមើលទំនាក់ទំនងគ្រួសារតាមអនឡាញនៅតាមគេហទំព័រ www.familyrelationships.gov.au

អ្នកក៏អាចប្រើបញ្ជីដំណោះស្រាយវិវាទគ្រួសារ (https://fdrr.ag.gov.au/) ដើម្បីស្វែងរកអ្នកប្រកបវិជ្ជាជីវៈ FDR ឯកជនផងដែរ។ អ្នកអាចប្រើប្រាស់ផែនទីដើម្បីស្វែងរកអ្នកប្រកបវិជ្ជាជីវៈ ដែលនៅជិតអ្នក។

សម្រាប់ព័ត៌មានបន្ថែមអំពីទីភ្នាក់ងារគ្រប់គ្រងប្រាក់ជំនួយឧបត្ថម្ភកូន សូមចូលមើលគេហទំព័រ https://www.servicesaustralia.gov.au/